## Expressing thirst



ទិញភេសជ្ជៈ

វីរៈ៖ ស្រេកទឹកអំា។ ង៉ៃហ្នឹងក្ដៅម៉េះហ្ន៎? បែកញើសឡើងជោកហើយ។ ចូលទិញទឹកផឹកតិចសិន។ អ្នកលក់ មានទឹកសុទ្ធអ៎េ?

អ្នកលក់៖ មាន តែអត់មានអាត្រជាក់ផង។ អាក្លាសេអស់ហើយ អត់ទាន់បានដាក់ក្លាសេទៀតផង។

វីរៈ៖ ចង់បានអាត្រជាក់។ ចុះមានអីខ្លះក្នុងធុងទឹកកកហ្នឹង?

អ្នកលក់៖ មានទឹកក្រូច ទឹកផ្លែឈើ ...

វីរៈ៖ យកកូកាមួយម៉ោអីចឹង។ ... យកពីរកំប៉ុងម៉ងទៅ ទុកផឹកតាមផ្លូវទៀត។ បើកផឹកម៉ាក្អឹកសិន ចាំទៅមុខទៀត។

អ្នកលក់៖ អង្គុយសម្រាកនៅនោះសិនទៅ។ ប្រយ័ត្នខ្យល់គរ។

ក្រោយការប្រជុំ

វីរៈ៖ និយាយច្រើនពេក ឥឡូវខះកហើយ។ ជាតាស្រេកទឹកអត់? រកទិញអីផឹកសិនអី?

សុជាតា៖ ខ្ញុំអត់សូវស្រេកម៉ានផង ប៉ុន្តែ មានអី ទៅទិញជាមួយគ្នាបានតាស។ ខ្ញុំចង់ផឹកកាហ្វេឡាតេ។ វីរៈឯងស្ងួតកអីចឹង ដាក់តែក្រូចឆ្មារទៅឆាប់បាត់ស្រេក។

| | |
|---|---|
| វីរៈ | male Cambodian name |
| អំា | emphatic particle |
| ង៉ៃ | spoken form of ថ្ងៃ = day |
| ហ្ន៎ | final particle to soften a statement or request, similar to ណា |
| ទឹកសុទ្ធ | spoken form of ទឹកបរិសុទ្ធ = mineral/disinfected water |
| អ៎េ | spoken form of the negation or question particle ទេ |
| អា + adj. | [the] one that [is] + adj. |
| ក្លាសេ | iced, refridgerated (French: glacé) |
| ធុងទឹកកក | ice box |
| កូកា | coca cola |
| ម៉ោ | spoken form of មក = to come |

Copyright © 2018 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

| | |
|---|---|
| ម៉ង | spoken form of តែម្តង |
| ម៉ាក្បឿក | a sip, also ម៉ាក្អឹក, មួយក្អឹក |
| ... ចាំទៅមុខទៀត | ... before going further |
| ខ្យល់គរ | to faint |
| សុជាតា, short: ជាតា | female Cambodian name |
| ខះក | to have a sore or dry throat |
| អត់សូវ + adj. + ម៉ានផង | not so/that + adj., not particularly + adj., not very + adj. |
| មានអី | ok |
| តាស | affirmative particle |
| កាហ្វេឡាតេ | latte (a kind of coffee) |
| តែក្រូចឆ្មារ | lemon tea |
| បាត់ស្រេក | to be no longer thirsty |

## Cultural notes

នៅប្រទេសកម្ពុជា មានអាកាសធាតុក្តៅស្ទើរពេញមួយឆ្នាំ ដូច្នេះមានតូបលក់ភេសជ្ជៈឬហាងកាហ្វេជាច្រើន។ ទឹកអំពៅមានរសជាតិផ្អែម ជាភេសជ្ជៈពេញនិយមតាំងពីដើមមក។ ភេសជ្ជៈកំប៉ុងដែលជនជាតិខ្មែរស្គាល់ច្រើនជាងគេគឺកូកា ហ្វាន់តា ប៉ិបស៊ី ទឹកផ្លែឈើ ដូចជាទឹកត្រឡាច ទឹកចាហួយ ។ល។ លក្ខណៈពិសេសរបស់ហាងកាហ្វេដែលជនជាតិខ្មែរចូលចិត្តគឺហាងកាហ្វេមានម៉ាស៊ីនត្រជាក់ មានវ៉ាយហ្វាយលេងអ៊ីនធឺណិត ហើយអាចអង្គុយបានយូរ។

| | |
|---|---|
| ទឹកអំពៅ | sugar cane juice |
| ហ្វាន់តា / ប៉ិបស៊ី | fanta / pepsi |
| ទឹកត្រឡាច | canned drink with wax gourd flavor or fragrance |
| ទឹកចាហួយ | canned drink with small black jelly pieces |
| វ៉ាយហ្វាយ | wifi |

## Additional dialogue

ម្តាយ៖ ម៉ោញ៉ាំបាយ កូន!
កូន៖ ដូចអត់ឃ្លានអេះម៉ាក់។ ស្រេកតែទឹក។
ម្តាយ៖ ញ៉ាំតិចទៅ។ មានសម្លដៃរតាស។
កូន៖ ផឹកតែទឹក ឆ្អែតបាត់ហើយម៉ាក់។ ចាំតិចទៀតចាំញ៉ាំ គ្របទុកសិនទៅ។

| | |
|---|---|
| គ្របទុក | to cover and keep the food (for later consumption) |

Copyright © 2018 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.